រៀបរៀងដោយ លឹម ផល្គុន

117 លំហាត់ វិសមភាពជ្រើសរើស

$$a+b \geq \sqrt{\frac{a^2+b^2}{2}}+\sqrt{ab}$$

$$\frac{1}{(a+b)^2}+\frac{1}{(b+c)^2}+\frac{1}{(c+a)^2} \geq \frac{9}{4(ab+bc+ca)}$$

$$\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b} \geq \frac{3}{2}$$

Problem and Solution

ជំពូកទី១

លំហាត់ជ្រើសរើស

1. ចូរស្រាយបញ្ជាក់ថា $a+b \geq \sqrt{\frac{a^2+b^2}{2}}+\sqrt{ab}$

គ្រប់ចំនួនពិតវិជ្ជមាន a និង b ។

2. ចូរស្រាយបញ្ជាក់ថាចំពោះគ្រប់ $a, b, c \geq 0$ គេមានវិសមភាព

$$(a+b)(b+c)(a+c) \geq \frac{8}{9}(a+b+c)(ab+bc+ca)$$

3. ចូរបង្ហាញថា $\frac{(a+b)(b+c)(c+a)}{(a+b+c)^3} \leq \frac{8}{27}$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b, c ។

4. គេឱ្យចំនួនពិតវិជ្ជមាន a, b, c, x, y, z ។

ចូរស្រាយថា $\sqrt[3]{(x+a)(y+b)(z+c)} \geq \sqrt[3]{xyz}+\sqrt[3]{abc}$

5. ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b និង c ចូរស្រាយបញ្ជាក់ថា :

$$\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b} \geq \frac{3}{2}$$ ។

6. គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា $\frac{1}{(x+y)^2}+\frac{1}{(y+z)^2}+\frac{1}{(z+x)^2} \geq \frac{2(x+y+z)}{(x+y)(y+z)(x+z)}$

7. ចូរស្រាយបញ្ជាក់វិសមភាព :

$$\sqrt{a^2+(1-b)^2}+\sqrt{b^2+(1-c)^2}+\sqrt{c^2+(1-a)^2}\geq\frac{3\sqrt{2}}{2}$$

ចំពោះគ្រប់ចំនួនពិត a,b,c ។

8. បើ $a,b,c\in(0,1)$ ចូរបង្ហាញថា :

$$\sqrt{abc}+\sqrt{(1-a)(1-b)(1-c)}<1$$

9.គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរស្រាយថា $\dfrac{a+b}{\sqrt{c}}+\dfrac{b+c}{\sqrt{a}}+\dfrac{c+a}{\sqrt{b}}\geq\sqrt{a}+\sqrt{b}+\sqrt{c}+3$

10. គេឱ្យ a,b,c,d ជាបួនចំនួនពិតដែល $a^2+b^2+c^2+d^2=4$ ។

ចូរស្រាយបញ្ជាក់ថា $a^3+b^3+c^3+d^3\leq 8$ ។

11. គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមាន ។

ចូរស្រាយថា $a^3+b^3+c^3-3abc\geq 2\left(\dfrac{b+c}{2}-a\right)^3$ ។

12. គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរបង្ហាញថា $\dfrac{a+b+c}{3}\geq\sqrt[5]{\dfrac{a^2+b^2+c^2}{3}}$ ។

13. គេឱ្យ a,b,c ជាបីចំនួនពិតខុសគ្នា ។

ចូរស្រាយថា $\dfrac{a^2}{(b-c)^2}+\dfrac{b^2}{(c-a)^2}+\dfrac{c^2}{(a-b)^2}\geq 2$ ។

14. គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមានដែល $a^2+b^2+c^2=a+b+c$

ចូរស្រាយថា $a^2b^2+b^2c^2+c^2a^2\le ab+bc+ca$ ។

15. គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមាន ។ ចូរស្រាយថា :

$$(a^2+ab+b^2)(b^2+bc+c^2)(c^2+ca+a^2)\ge(ab+bc+ca)^3$$

16. គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមានដែល $abc=1$ ។ ចូរស្រាយថា :

$$\frac{c\sqrt{a^3+b^3}}{a^2+b^2}+\frac{a\sqrt{b^3+c^3}}{b^2+c^2}+\frac{b\sqrt{c^3+a^3}}{c^2+a^2}\ge\frac{3}{\sqrt{2}}$$ ។

17. គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់វិសមភាព :

$$\sqrt{\frac{a^3}{a^3+(b+c)^3}}+\sqrt{\frac{b^3}{b^3+(c+a)^3}}+\sqrt{\frac{c^3}{c^3+(a+b)^3}}\ge 1$$ ។

18. ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c ចូរស្រាយថា :

$$\sqrt{\frac{a}{a+b}}+\sqrt{\frac{b}{b+c}}+\sqrt{\frac{c}{c+a}}\le\frac{3}{\sqrt{2}}$$

19. ចំពោះគ្រប់ចំនួនពិតមិនអវិជ្ជមាន x,y,z ចូរស្រាយថា :

$$2(1+x^2)(1+y^2)(1+z^2)\ge(1+x)(1+y)(1+z)(1+xyz)$$

20. ចំពោះគ្រប់ចំនួនពិតមិនអវិជ្ជមាន a,b,c,d ចូរស្រាយថា :

$$4(1-a+a^2)(1-b+b^2)(1-c+c^2)(1-d+d^2)\ge(1+abcd)^2$$

21. បើសមីការ $x^4+ax^3+2x^2+bx+1=0$ មានឫសយ៉ាងតិចមួយ

ជាចំនួនពិតនោះបង្ហាញថា $a^4+b^4\ge 8$ ។

22. ចូរស្រាយបញ្ជាក់ថា :

$$\frac{a}{(b+c)^2}+\frac{b}{(c+a)^2}+\frac{c}{(a+b)^2}\geq\frac{9}{4(a+b+c)}$$

ចំពោះគ្រប់ a,b,c ជាចំនួនពិតវិជ្ជមាន ។

23. ចូរស្រាយបញ្ជាក់ថា $\frac{a^3}{b^2}+\frac{b^3}{c^2}+\frac{c^3}{a^2}\geq\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}$

ចំពោះគ្រប់ a,b,c ជាចំនួនពិតវិជ្ជមាន ។

24. គេឱ្យ x,y,z ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{x}{x+\sqrt{(x+y)(x+z)}}+\frac{y}{y+\sqrt{(y+z)(y+x)}}+\frac{z}{z+\sqrt{(z+x)(z+y)}}\leq 1$$

25. គ្រប់ចំនួនពិតវិជ្ជមាន a,b,c ចូរស្រាយបញ្ជាក់ថា :

$$\frac{b+c}{a}+\frac{c+a}{b}+\frac{a+b}{c}\geq 4\left(\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\right)$$

26. គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរស្រាយថា $(a+b)(b+c)(c+a)\geq 4(a+b+c-1)$

27. ចូរបង្ហាញថា $(a^2+2)(b^2+2)(c^2+2)\geq 9(ab+bc+ca)$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c ។

28. គេយក a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{(b+c-a)^2}{(b+c)^2+a^2}+\frac{(c+a-b)^2}{(c+a)^2+b^2}+\frac{(a+b-c)^2}{(a+b)^2+c^2}\geq\frac{3}{5}$$

29. គេឱ្យ x,y,z,t ជាបួនចំនួនពិតវិជ្ជមាន ។ ចូរស្រាយថា :

$$\left(\frac{x}{x+y}\right)^2+\left(\frac{y}{y+z}\right)^2+\left(\frac{z}{z+t}\right)^2+\left(\frac{t}{t+x}\right)^2\ge 1$$ ។

30. គេឱ្យ a,b,c និង x,y,z ជាចំនួនពិត ។ ចូរស្រាយបញ្ជាក់ថា :

$$4(a^2+x^2)(b^2+y^2)(c^2+z^2)\ge 3(bcx+cay+abz)^2$$

31. គេឱ្យបីចំនួនពិត $a>-1$, $b>-1$, $c>-1$ ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{1+a^2}{1+b+c^2}+\frac{1+b^2}{1+c+a^2}+\frac{1+c^2}{1+a+b^2}\ge 2$$ ។

32. គេឱ្យបីចំនួនពិតវិជ្ជមាន a,b,c ដែល $abc=1$ ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{1}{(1+a)^3}+\frac{1}{(1+b)^3}+\frac{1}{(1+c)^3}\ge\frac{3}{8}$$ ។

33. គេឱ្យបីចំនួនពិតវិជ្ជមាន a,b,c ដែល $a^2+b^2+c^2+(a+b+c)^2\le 4$

ចូរស្រាយបញ្ជាក់ថា $$\frac{ab+1}{(a+b)^2}+\frac{bc+1}{(b+c)^2}+\frac{ca+1}{(c+a)^2}\ge 3$$ ។

34. គេឱ្យបីចំនួនពិតវិជ្ជមាន a,b និង c ។ ចូរស្រាយថា

$$(a^5-a^2+3)(b^5-b^2+3)(c^5-c^2+3)\ge(a+b+c)^3$$

35. ចូរស្រាយថាចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c គេមានវិសមភាព :

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc}$$ ។

36. គេយក $a=\dfrac{m^{m+1}+n^{n+1}}{m^m+n^n}$ ដែល m និង n ជាចំនួនគត់វិជ្ជមាន ។

ចូរស្រាយថា $a^m+a^n\geq m^m+n^n$ ។

37. គេឱ្យ $x\,;\,y\,;\,z$ ជាបីចំនួនពិតវិជ្ជមានដែល $xyz=1$ ។

ចូរស្រាយបញ្ជាក់ថា :

$$\frac{x^9+y^9}{x^6+x^3y^3+y^6}+\frac{y^9+z^9}{y^6+y^3z^3+z^6}+\frac{z^9+x^9}{z^6+z^3x^3+x^6}\geq 2$$

38. គេឱ្យ $a\,,\,b\,,c$ ជាចំនួនវិជ្ជមានដែល $ab+bc+ca=3$ ។

ចូរបង្ហាញថា $\dfrac{1}{1+a^2(b+c)}+\dfrac{1}{1+b^2(c+a)}+\dfrac{1}{1+c^2(a+b)}\leq\dfrac{1}{abc}$

39. គេឱ្យ a និង b ជាពីរចំនួនពិតមិនអវិជ្ជមានដែល $a^2+b^2=4$ ។

ចូរស្រាយថា $\dfrac{ab}{a+b+2}\leq\sqrt{2}-1$ ។

40. ចូរស្រាយថា $\dfrac{x^3+y^3+z^3}{3}\geq xyz+\dfrac{3}{4}|(x-y)(y-z)(z-x)|$

ចំពោះគ្រប់ $x\,;\,y\,;\,z\geq 0$ ។

41. គេឱ្យ $a\,,\,b\,,\,c$ ជាប្រវែងជ្រុងនៃត្រីកោណមួយ ។

ចូរស្រាយថា $\dfrac{a}{b-a+c}+\dfrac{b}{a-b+c}+\dfrac{c}{a+b-c}\geq 3$ ។

42. គេឱ្យ $a, b\,,\,c$ ជាបីចំនួនពិតដែលផ្ទៀងផ្ទាត់ $a^2+b^2+c^2=3$ ។

ចូរបង្ហាញថា $|a|+|b|+|c|-abc\leq 4$ ។

43. គេឱ្យ a, b, c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរបង្ហាញថា $1+\frac{3}{a+b+c}\ge\frac{6}{ab+bc+ca}$ ។

44. គេឱ្យ $a\ge 1$ និង $b\ge 1$ ។

ចូរបង្ហាញថា $\sqrt{\log_2 a}+\sqrt{\log_2 b}\le 2\sqrt{\log_2\left(\frac{a+b}{2}\right)}$ ។

45. គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ $xyz=1$ ។

ចូរបង្ហាញវិសមភាព :

$$\frac{(x+y-1)^2}{z}+\frac{(y+z-1)^2}{x}+\frac{(z+x-1)^2}{y}\ge x+y+z$$ ។

46.គេឱ្យ a, b, c ជាចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា $\frac{a^2b(b-c)}{a+b}+\frac{b^2c(c-a)}{b+c}+\frac{c^2a(a-b)}{c+a}\ge 0$ ។

47. គេឱ្យ a, b, c ជាបីចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{a^5+b^5+c^5-(a+b+c)^5}{a^3+b^3+c^3-(a+b+c)^3}\ge\frac{10}{9}(a+b+c)^2$$

48. ចំពោះគ្រប់ចំនួនពិត $x\in(0,\frac{\pi}{4})$

ចូរបង្ហាញថា $(\cos x)^{\cos x}>(\sin x)^{\sin x}$ ។

49. គេឱ្យ a, b, c, d ជាបីចំនួនពិតដែលផ្ទៀងផ្ទាត់វិសមភាព :

$$(a^2+b^2-1)(c^2+d^2-1)>(ac+bd-1)^2$$

ចូរបង្ហាញថា $a^2+b^2>1$ និង $c^2+d^2>1$ ។

50. គេឱ្យ a, b, c ជាបីចំនួនពិតវិជ្ជមានដែល $\sqrt{ab}+\sqrt{bc}+\sqrt{ca}=1$ ។

ចូរកំនត់តម្លៃអប្បបរមានៃកន្សោម $E=\dfrac{a^2}{a+b}+\dfrac{b^2}{b+c}+\dfrac{c^2}{c+a}$ ។

51. គេឱ្យ $x_1, x_2, ..., x_n$ (ដែល $n\geq 2$) ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ :

$$\frac{1}{x_1+1998}+\frac{1}{x_2+1998}+....+\frac{1}{x_n+1998}=\frac{1}{1998}$$

ចូរបង្ហាញថា $\dfrac{\sqrt[n]{x_1.x_2...x_n}}{n-1}\geq 1998$ ។

52. គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែល $xyz=x+y+z$ ។

ចូរស្រាយថា $\dfrac{x+y}{1+z^2}+\dfrac{y+z}{1+x^2}+\dfrac{z+x}{1+y^2}\geq\dfrac{27}{2xyz}$ ។

53. ចូរបង្ហាញថាបើ $abc=8$ និង $a, b, c>0$ នោះគេបាន :

$$\frac{a^2}{\sqrt{(1+a^3)(1+b^3)}}+\frac{b^2}{\sqrt{(1+b^3)(1+c^3)}}+\frac{c^2}{\sqrt{(1+c^3)(1+a^3)}}\geq\frac{4}{3}$$

54. គេឱ្យត្រីកោណ ABC មួយមានជ្រុង $BC=a$, $AC=b$, $AB=c$

ហើយមានមុំក្នុងជាមុំស្រួច ។

ចូរស្រាយថា $\dfrac{a+b}{\cos C}+\dfrac{b+c}{\cos A}+\dfrac{c+a}{\cos B}\geq 4(a+b+c)$

55. គេឱ្យ $x, y, z > 0$ ដែល $x + y + z = 1$ ។

ចូរស្រាយថា $\dfrac{x^3}{(1-x)^2} + \dfrac{y^3}{(1-y)^2} + \dfrac{z^3}{(1-z)^2} \geq \dfrac{1}{4}$ ។

56. គេឱ្យ a, b, c, d ជាចំនួនពិតវិជ្ជមានដែល $abcd = 1$ ។

បើគេដឹងថា $a + b + c + d > \dfrac{a}{b} + \dfrac{b}{c} + \dfrac{c}{d} + \dfrac{d}{a}$ នោះចូរបង្ហាញថា

$a + b + c + d < \dfrac{b}{a} + \dfrac{c}{b} + \dfrac{d}{c} + \dfrac{a}{d}$ ។

បង្ហាញថា $a + b + c + d < \dfrac{b}{a} + \dfrac{c}{b} + \dfrac{d}{c} + \dfrac{a}{d}$

57. គេយក a, b, c ជាចំនួនវិជ្ជមានដែលផ្ទៀងផ្ទាត់ $abc = 1$ ។

ចូរបង្ហាញថា $\dfrac{a}{(a+1)(b+1)} + \dfrac{b}{(b+1)(c+1)} + \dfrac{c}{(c+1)(a+1)} \geq \dfrac{3}{4}$ ។

58. គេយក a, b, c ជាចំនួនវិជ្ជមាន ។

ចូរបង្ហាញថា $(1+\dfrac{a}{b})(1+\dfrac{b}{c})(1+\dfrac{c}{a}) \geq 2(1+\dfrac{a+b+c}{\sqrt[3]{abc}})$ ។

59. គេយក a, b, c ជាចំនួនពិតនៃចន្លោះ $(0,1)$ ។

ចូរបង្ហាញថា $\sqrt{abc} + \sqrt{(1-a)(1-b)(1-c)} < 1$ ។

60. គេយក a, b, c ជាចំនួនពិតវិជ្ជមានដែល $ab + bc + ca = abc$

ចូរបង្ហាញថា $\dfrac{a^4+b^4}{ab(a^3+b^3)} + \dfrac{b^4+c^4}{bc(b^3+c^3)} + \dfrac{c^4+a^4}{ca(c^3+a^3)} \geq 1$ ។

61. គេយក x , y , z ជាចំនួនពិតវិជ្ជមានដែល $xyz = 1$

ចូរបង្ហាញថា $\frac{1}{yz+z}+\frac{1}{zx+x}+\frac{1}{xy+y}\geq\frac{3}{2}$ ។

62. ចំនួនពិត $a, , b , c , x , y , z$ ផ្ទៀងផ្ទាត់ $a\geq b\geq c>0$

និង $x\geq y\geq z>0$ ។ ចូរបង្ហាញថា

$$\frac{a^2x^2}{(by+cz)(bz+cy)}+\frac{b^2y^2}{(cz+ax)(cx+az)}+\frac{c^2z^2}{(ax+by)(ay+bx)}\geq\frac{3}{4}$$ ។

63. ចូរបង្ហាញថា $\frac{x}{1-x}+\frac{y}{1-y}+\frac{z}{1-z}\geq\frac{3\sqrt[3]{xyz}}{1-\sqrt[3]{xyz}}$

ចំពោះគ្រប់ $0<x , y , z<1$ ។

64. ចូរបង្ហាញថាចំពោះគ្រប់ a , b , c ជាចំនួនពិតវិជ្ជមានគេបាន :

$$\frac{a}{\sqrt{a^2+8bc}}+\frac{b}{\sqrt{b^2+8ca}}+\frac{c}{\sqrt{c^2+8ab}}\geq 1$$ ។

បង្ហាញថា $\frac{a}{\sqrt{a^2+8bc}}+\frac{b}{\sqrt{b^2+8ca}}+\frac{c}{\sqrt{c^2+8ab}}\geq 1$

65. ចូរបង្ហាញថាចំពោះគ្រប់ a , b , c ជាចំនួនពិតវិជ្ជមានគេបាន :

$$\frac{(a+1)(b+1)^2}{3\sqrt[3]{c^2a^2}+1}+\frac{(b+1)(c+1)^2}{3\sqrt[3]{a^2b^2}+1}+\frac{(c+1)(a+1)^2}{3\sqrt[3]{b^2c^2}+1}\geq a+b+c+3$$ ។

66. គេឱ្យ x , y , z ជាចំនួនពិតវិជ្ជមានដែល $\sqrt{x}+\sqrt{y}+\sqrt{z}=1$ ។

ចូរស្រាយថា :

$$\frac{x^2+yz}{\sqrt{2x^2(y+z)}}+\frac{y^2+zx}{\sqrt{2y^2(z+x)}}+\frac{z^2+xy}{\sqrt{2z^2(x+y)}}\geq 1$$ ។

67. បើចំនួនពិតវិជ្ជមាន a , b , c ផ្ទៀងផ្ទាត់ $a^2+b^2+c^2=3$

នោះចូរបង្ហាញថា :

$$\frac{a^2}{2+b+c^2}+\frac{b^2}{2+c+a^2}+\frac{c^2}{2+a+b^2}\geq\frac{(a+b+c)^2}{12}$$ ។

68. គេមានចំនួនពិតវិជ្ជមាន a , b , c ផ្ទៀងផ្ទាត់ $a+b+c=1$ ។

ចូរបង្ហាញថា $\frac{a-bc}{a+bc}+\frac{b-ca}{b+ca}+\frac{c-ab}{c+ab}\leq\frac{3}{2}$ ។

69. គេឱ្យ a , b , c ជា ចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា $\frac{1}{a^2+bc}+\frac{1}{b^2+ca}+\frac{1}{c^2+ab}\leq\frac{1}{2}(\frac{1}{ab}+\frac{1}{bc}+\frac{1}{ca})$ ។

70. គេឱ្យ a , b , c , d ជាចំនួនពិតវិជ្ជមាន ។

$$S=\frac{a^4}{(a+b)(a^2+b^2)}+\frac{b^4}{(b+c)(b^2+c^2)}+\frac{c^4}{(c+d)(c^2+d^2)}+\frac{d^4}{(d+a)(d^2+a^2)}$$

ចូរបង្ហាញថា $S\geq\frac{a+b+c+d}{4}$ ។

71. គេឱ្យចំនួនពិតវិជ្ជមាន $x_1 , x_2 , ... , x_n$ ហើយគេតាង

$S_n=x_1+x_2+...+x_n$ ។ ចូរស្រាយថា :

$$(1+x_1)(1+x_2)....(1+x_n)\leq 1+S+\frac{S^2}{2!}+...+\frac{S^n}{n!}$$

72. ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n និង ចំពោះគ្រប់ចំនួនពិតវិជ្ជមាន

$a_1, a_2, ..., a_n$ ផ្ទៀងផ្ទាត់ $a_1a_2a_3....a_n = 1$ ។

ចូរបង្ហាញថា : $\sum_{i=1}^{n} \frac{a_i}{\sqrt{a_i^4+3}} \le \frac{1}{2}\sum_{i=1}^{n}\frac{1}{a_i}$ ។

73. គេឱ្យ a, b, c ជាចំនួនពិតវិជ្ជមាន ដោយដឹងថា

$\frac{1}{a}+\frac{1}{b}+\frac{1}{c} = a+b+c$ ។ ចូរបង្ហាញថា :

$$\frac{1}{(2a+b+c)^2}+\frac{1}{(a+2b+c)^2}+\frac{1}{(a+b+2c)^2} \le \frac{3}{16}$$ ។

74. សមីការ $x^3 - ax^2 + bx - c = 0$ មានឫសបីជាចំនួនពិតវិជ្ជមាន

(មិនចាំបាច់ខុសគ្នា) ។

ចូរកំណត់តម្លៃអប្បបរមាដែលអាចនៃ $\frac{1+a+b+c}{3+2a+b} - \frac{c}{b}$ ។

75. ចូរស្រាយថា :

$$\sum_{Cyc}\sqrt[4]{\frac{(a^2+b^2)(a^2-ab+b^2)}{2}} \le \frac{2}{3}(a^2+b^2+c^2)\left(\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a}\right)$$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b, c ។

76. បើ a, b, c ជារង្វាស់ជ្រុងនៃត្រីកោណមួយ ហើយ r ជាកាំរង្វង់

ចារឹកក្នុងនៃត្រីកោណនោះចូរស្រាយថា $\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2} \le \frac{1}{4r^2}$ ។

77. គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមានហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ

$16(a+b+c)\geq \frac{1}{a}+\frac{1}{b}+\frac{1}{c}$ ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{1}{(a+b+\sqrt{2a+2c})^3}+\frac{1}{(b+c+\sqrt{2a+2b})^3}+\frac{1}{(c+a+\sqrt{2b+2c})^3}\leq\frac{8}{9}$$

78. គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមានដែល $a+b+c=1$ ។

ចូរបង្ហាញថា $\frac{ab}{1-c^2}+\frac{bc}{1-a^2}+\frac{ca}{1-b^2}\leq\frac{3}{8}$ ។

79. គេឱ្យ $a\ ,\ b\ ,\ c$ ជាបីចំនួនពិតមិនអវិជ្ជមាន និង $x,\ y\ ,\ z$

ជាបីចំនួនពិតវិជ្ជមានដោយដឹងថា $a+b+c=x+y+z$ ។

ចូរស្រាយបញ្ជាក់ថា : $\frac{a^3}{x^2}+\frac{b^3}{y^2}+\frac{c^3}{z^2}\geq a+b+c$ ។

80. គេឱ្យ $a\ ,\ b\ ,\ c>0$ ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{a+\sqrt[3]{4(b^3+c^3)}}{b+c}+\frac{b+\sqrt[3]{4(c^3+a^3)}}{c+a}+\frac{c+\sqrt[3]{4(a^3+b^3)}}{a+b}\geq\frac{9}{2}$$ ។

81. គេអោយបីចំនួនពិតវិជ្ជមាន a,b,c ។ ចូរស្រាយថា :

$$\frac{a^3}{(b+c)^3}+\frac{b^3}{(c+a)^3}+\frac{c^3}{(a+b)^3}\geq\frac{3}{8}$$ ។

82. ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c គេកំណត់តាង $A=\frac{a+b+c}{3}$

$G=\sqrt[3]{abc}$ និង $H=\frac{3}{\frac{1}{a}+\frac{1}{b}+\frac{1}{c}}$ ។

ចូរស្រាយថា $\left(\frac{A}{G}\right)^3\ge\frac{1}{4}+\frac{3}{4}.\frac{A}{H}$?

83. គេឱ្យចំនួនពិត x_1,x_2,y_1,y_2,z_1,z_2 ផ្ទៀងផ្ទាត់ $x_1>0,x_2>0$

$x_1y_1-z_1^{\,2}>0$ និង $x_2y_2-z_2^{\,2}>0$ ។

ចូរស្រាយបញ្ជាក់ថា :

$$\frac{8}{(x_1+x_2)(y_1+y_2)-(z_1+z_2)^2}\le\frac{1}{x_1y_1-z_1^{\,2}}+\frac{1}{x_2y_2-z_2^{\,2}}\ (*)$$

84. គេឱ្យត្រីកោណ ABC មួយមានមុំក្នុងជាមុំស្រួច ។ ចូរស្រាយថា :

$\sqrt{\cos A}+\sqrt{\cos B}+\sqrt{\cos C}\le\frac{3\sqrt{2}}{2}$ ។

85. គេឱ្យ $x\ ;\ y\ ;\ z$ ជាចំនួនពិតវិជ្ជមានដែល $xyz=1$ ។ ចូរស្រាយថា :

$$\frac{1}{(x+1)^2+y^2+1}+\frac{1}{(y+1)^2+z^2+1}+\frac{1}{(z+1)^2+x^2+1}\le\frac{1}{2}$$ ។

86. គេឱ្យ $a\ ;\ b\ ;\ c$ ជាចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរស្រាយថា :

$a(b^2-\sqrt{b})+b(c^2-\sqrt{c})+c(a^2-\sqrt{a})\ge 0$ ។

87. គេឱ្យ $a_1, a_2, ..., a_n > 0$ និង $x_1, x_2, ..., x_n > 0$ ។

ចូរស្រាយតាមកំណើនថា :

$$\frac{a_1^{\ 2}}{x_1} + \frac{a_2^{\ 2}}{x_2} + ... + \frac{a_n^{\ 2}}{x_n} \geq \frac{(a_1 + a_2 + ... + a_n)^2}{x_1 + x_2 + ... + x_n}$$ ។

88. គេឱ្យ $a\ ;\ b\ ;\ c$ ជាបីចំនួនពិតវិជ្ជមានដែល $abc = 1$ ។

ចូរបង្ហាញថា

$$\frac{1}{a^3(b+c)} + \frac{1}{b^3(c+a)} + \frac{1}{c^3(a+b)} \geq \frac{3}{2}$$?

89. គេឱ្យ $x\ ;\ y\ ;\ z > 0$ ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{x}{x+2y+3z} + \frac{y}{y+2z+3x} + \frac{z}{z+2x+3y} \geq \frac{1}{2}$$

90. គេឱ្យស្វ៊ីត $a_1 ; a_2 ; ....; a_n$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ :

$a_1 = 0 ; |a_2| = |a_1 + 1| ; ...$ និង $|a_n| = |a_{n-1} + 1|$ ។

ចូរបង្ហាញថា $\dfrac{a_1 + a_2 + ... + a_n}{n} \geq -\dfrac{1}{2}$ ។

91.គេឱ្យ $a ; b ; c$ ជាបីចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា :

$$\left(1+\frac{a}{b}\right)\left(1+\frac{b}{c}\right)\left(1+\frac{c}{a}\right) \geq 2\left(1+\frac{a+b+c}{\sqrt[3]{abc}}\right)$$ ។

92.គេឱ្យ $a\,;b\,;c$ ជាប្រវែងជ្រុងរបស់ត្រីកោណមួយ ។

ចូរបង្ហាញថា ៖

$$\sqrt{a+b-c}+\sqrt{b+c-a}+\sqrt{c+a-b}\le\sqrt{a}+\sqrt{b}+\sqrt{c}$$ ។

93.គេឱ្យត្រីកោណ ABC មួយមានមុំក្នុងជាមុំស្រួច ។ ចូរបង្ហាញថា ៖

$$\sin^2 A+\sin^2 B+\sin^2 C\ge 2\sqrt{3}\sin A\sin B\sin C$$ ។

94.គេឱ្យ $A\,;\,B\,;C$ ជាមុំក្នុងរបស់ត្រីកោណ ABC មួយ ។

ចូរបង្ហាញថា $\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}\ge 3\sqrt{3}$

95.គេឱ្យ $A\,;\,B\,;C$ ជាមុំស្រួចក្នុងរបស់ត្រីកោណ ABC មួយ ។

ចូរបង្ហាញថា $(1+\tan A)(1+\tan B)(1+\tan C)\ge(1+\sqrt{3})^3$ ។

96.គេឱ្យ $a\,;\,b\,;c$ ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយថា ៖

$$(a^2+2)(b^2+2)(c^2+2)\ge 9(ab+bc+ca)$$ ។

97.ប្រសិនបើ $xyx=(1-x)(1-y)(1-z)$ ដែល $0\le x;y;z\le 1$

ចូរបង្ហាញថា $x(1-z)+y(1-x)+z(1-y)\ge\frac{3}{4}$ ។

98.គេឱ្យ $a\,;\,b\,;\,c$ ជាប្រវែងជ្រុងរបស់ត្រីកោណមួយដែលមាន

បរិមាត្រស្មើ 2 ។

ចូរស្រាយថា $\frac{3}{2}<a^2+b^2+c^2+2abc<2$ ។

99.គេឱ្យ $x ; y ; z$ ជាបីចំនួនពិតវិជ្ជមានដែល $x+y+z=1$ ។

ចូរស្រាយបញ្ជាក់ថា $\left(\frac{1}{x}-1\right)\left(\frac{1}{y}-1\right)\left(\frac{1}{z}-1\right)\geq 8$ ។

100. គេឱ្យ $a ; b ; c$ ជាបីចំនួនពិតវិជ្ជមានដែល $a^2+b^2+c^2=1$

បង្ហាញថា $\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}\geq 3+\frac{2(a^3+b^3+c^3)}{abc}$

101. គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{a^2}{\sqrt{2a^2+ab+b^2}}+\frac{b^2}{\sqrt{2b^2+bc+c^2}}+\frac{c^2}{\sqrt{2c^2+ca+a^2}}\geq\frac{a+b+c}{2}$$

102. គេឱ្យបីចំនួនពិតវិជ្ជមាន a,b,c ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{29a^3-b^3}{ab+6a^2}+\frac{29b^3-c^3}{bc+6b^2}+\frac{29c^3-a^3}{ca+6c^2}\leq 4(a+b+c)$$

103. គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់វិសមភាព :

$$\frac{a^3}{a^2+ab+b^2}+\frac{b^3}{b^2+bc+c^2}+\frac{c^3}{c^2+ca+a^2}\geq\frac{a+b+c}{3}$$

104. គេឱ្យបីចំនួនពិតវិជ្ជមាន a,b,c ដែល $a+b+c=1$ ។

ចូរស្រាយបញ្ជាក់ថា :

$$\frac{1}{ab+2c^2+2c}+\frac{1}{bc+2a^2+2a}+\frac{1}{ca+2b^2+2b}\geq\frac{1}{ab+bc+ca}$$

105. គេឱ្យត្រីកោណ ABC មួយមានជ្រុង $BC=a$, $CA=b$, $AB=c$

ហើយមុំក្នុង A,B,C ជាមុំស្រួចឬមុំកែង ។

តាង S ជាផ្ទៃក្រឡានៃ $\Delta\ ABC$

ចូរស្រាយបញ្ជាក់ថា $\frac{1}{a^4}+\frac{1}{b^4}+\frac{1}{c^4}\geq\frac{9}{16S^2}$ ។

106. ចូរបង្ហាញថា $\frac{1}{(x-y)^2}+\frac{1}{(y-z)^2}+\frac{1}{(z-x)^2}\geq\frac{4}{xy+yz+zx}$

ចំពោះគ្រប់ចំនួនពិតមិនអវិជ្ជមានខុសគ្នា x,y,z ។

107. ចូរបង្ហាញថា $\frac{1}{\frac{1}{a}+\frac{1}{b}}+\frac{1}{\frac{1}{c}+\frac{1}{d}}\leq\frac{1}{\frac{1}{a+c}+\frac{1}{b+d}}$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c,d ។

108. គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{(2a+b+c)^2}{2a^2+(b+c)^2}+\frac{(2b+c+a)^2}{2b^2+(c+a)^2}+\frac{(2c+a+b)^2}{2c^2+(a+b)^2}\leq 8$$

109.គេយក x ជាចំនួនពិត ដោយដឹងថា $0<x<\frac{\pi}{2}$ ។

ចូរបង្ហាញថា $\cos^2(x)\cot(x)+\sin^2(x)\tan(x)\geq 1$ ។

110. ស្វ៊ីត $\{a_n\}$ កំណត់ដោយ $a_1 = \frac{21}{16}$

និងចំពោះ $n \geq 2 : 2a_n - 3a_{n-1} = \frac{3}{2^{n+1}}$

គេយក m ជាចំនួនគត់មួយដែល $m \geq 2$ ។

ចូរបង្ហាញថាចំពោះ $n \leq m$ យើងបាន :

$$\left(a_n + \frac{3}{2^{n+3}}\right)^{\frac{1}{m}} \left(m - \left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right) < \frac{m^2 - 1}{m - n + 1} \quad ?$$

111. គេឱ្យ a, b, c ជាចំនួនពិតវិជ្ជមានដែល $a + b + c = 3$ ។

ចូរស្រាយបញ្ជាក់វិសមភាព $\frac{a^2}{a + b^2} + \frac{b^2}{b + c^2} + \frac{c^2}{c + a^2} \geq \frac{3}{2}$

112. គេឱ្យ a, b, c ជាជ្រុងរបស់ត្រីកោណមួយ ។ ចូរស្រាយថា :

$$\frac{(c+a-b)^4}{a(a+b-c)} + \frac{(a+b-c)^4}{b(b+c-a)} + \frac{(b+c-a)^4}{c(c+a-b)} \geq ab + bc + ca \quad ។$$

113. គេកំណត់ចំនួន $a_0, a_1, a_2, ..., a_n$ ដូចខាងក្រោម :

$$a_0 = \frac{1}{2}; a_{k+1} = a_k + \frac{{a_k}^2}{n} \quad (\, n > 1, k = 0, 1, 2, ..., n-1 \,)$$

ចូរបង្ហាញថា $1 - \frac{1}{n} < a_n < 1$ ។

114. ចំពោះគ្រប់ a, b, c ធំជាងមួយ ចូរបង្ហាញថា :

$$\log_a bc + \log_b ca + \log_c ab \geq 4(\log_{ab} c + \log_{bc} a + \log_{ca} b)$$

115. គេតាង α,β,γ ជារង្វាស់មុំក្នុងត្រីកោណ ABC មួយដែលមានបរិមាត្រ $2p$ និងកាំរង្វង់ចារឹកក្រៅ R ។

a/ ចូរស្រាយបញ្ជាក់ថា :

$$\cot^2\alpha+\cot^2\beta+\cot^2\gamma\geq 3\left(9.\frac{R^2}{p^2}-1\right)$$

b/ តើពេលណាទើបគេបានសមភាព ?

116. គេយក a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{(b+c-a)^2}{(b+c)^2+a^2}+\frac{(c+a-b)^2}{(c+a)^2+b^2}+\frac{(a+b-c)^2}{(a+b)^2+c^2}\geq\frac{3}{5}$$ ។

117. គេឱ្យបីចំនួនពិតមិនអវិជ្ជមាន a,b,c និងមិនសូន្យព្រមគ្នាពីរ ។

ចូរស្រាយបញ្ជាក់ថា :

$$(ab+bc+ca)\left[\frac{1}{(a+b)^2}+\frac{1}{(b+c)^2}+\frac{1}{(c+a)^2}\right]\geq\frac{9}{4}$$

www.mathtoday.wordpress.com

ជំពូកទី២

ផ្នែកដំណោះស្រាយ

លំហាត់ទី១

ចូរស្រាយថា $a+b \geq \sqrt{\frac{a^2+b^2}{2}}+\sqrt{ab}$ គ្រប់ចំនួនពិតវិជ្ជមាន a និង b

ឧបមាថា $a+b \geq \sqrt{\frac{a^2+b^2}{2}}+\sqrt{ab}$ ពិត

លើកអង្គទាំងពីរនៃវិសមភាពជាការេគេបាន :

$$(a+b)^2 \geq \left(\sqrt{\frac{a^2+b^2}{2}}+\sqrt{ab}\right)^2$$

$$a^2+2ab+b^2 \geq \frac{a^2+b^2}{2}+2\sqrt{ab}\,.\sqrt{\frac{a^2+b^2}{2}}+ab$$

$$a^2+2ab+b^2-\frac{a^2+b^2}{2}-2\sqrt{ab}\,.\sqrt{\frac{a^2+b^2}{2}}-ab \geq 0$$

$$\frac{a^2+b^2}{2}-2\sqrt{ab}.\sqrt{\frac{a^2+b^2}{2}}+ab=\left(\sqrt{\frac{a^2+b^2}{2}}-\sqrt{ab}\right)^2 \geq 0$$

ដូចនេះ $a+b \geq \sqrt{\frac{a^2+b^2}{2}}+\sqrt{ab}$ ។

លំហាត់ទី២

ចូរស្រាយបញ្ជាក់ថាចំពោះគ្រប់ $a,b,c\geq 0$ គេមានវិសមភាព

$$(a+b)(b+c)(a+c)\geq \frac{8}{9}(a+b+c)(ab+bc+ca)$$

គេមានសមភាព

$$(a+b)(b+c)(c+a)=a^2b+a^2c+ab^2+b^2a+ac^2+bc^2+2abc$$

$$(a+b+c)(ab+bc+ca)=a^2b+a^2c+ab^2+ab^2+ac^2+bc^2+3abc$$

ធ្វើផលដកសមភាពពីរនេះគេបាន

$$(a+b+c)(ab+bc+ca)-(a+b)(b+c)(c+a)=abc\ (1)$$

តាមវិសមភាព $AM-GM$ គេមាន $\begin{cases} a+b\geq 2\sqrt{ab} \\ b+c\geq 2\sqrt{bc} \\ c+a\geq 2\sqrt{ac} \end{cases}$

គេបាន $(a+b)(b+c)(c+a)\geq 8abc\quad (2)$

យក (1) ជំនួសក្នុង (2) គេបាន ៖

$$9(a+b)(b+c)(c+a)\geq 8(a+b+c)(ab+bc+ca)$$

ដូចនេះ $(a+b)(b+c)(a+c)\geq \dfrac{8}{9}(a+b+c)(ab+bc+ca)$ ។

លំហាត់ទី៣

ចូរបង្ហាញថា $\frac{(a+b)(b+c)(c+a)}{(a+b+c)^3} \le \frac{8}{27}$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b, c ។

តាមវិសមភាព $AM - GM$ គេមាន :

$$(a+b)+(b+c)+(c+a) \ge 3\sqrt[3]{(a+b)(b+c)(a+c)}$$

$$2(a+b+c) \ge 3\sqrt[3]{(a+b)(b+c)(c+a)}$$

លើកអង្គទាំងពីរជាស្វ័យគុណ 3 គេបាន :

$$8(a+b+c)^3 \ge 27(a+b)(b+c)(c+a)$$

ដូចនេះ $\frac{(a+b)(b+c)(c+a)}{(a+b+c)^3} \le \frac{8}{27}$ ។

លំហាត់ទី៤

គេឱ្យចំនួនពិតវិជ្ជមាន a,b,c,x,y,z ។

ចូរស្រាយថា $\sqrt[3]{(x+a)(y+b)(z+c)} \geq \sqrt[3]{xyz}+\sqrt[3]{abc}$

គេមាន :

$$(x+a)(y+b)(z+c)=xyz+ayz+bxz+cxy+abz+acy+bcx+abc$$

តាមវិសមភាព $AM-GM$ គេមាន :

$$ayz+bxz+cxy \geq 3\sqrt[3]{abcx^2y^2z^2}$$

$$abz+acy+bcx \geq 3\sqrt[3]{a^2b^2c^2xyz}$$

គេបាន :

$$(x+a)(y+b)(z+x) \geq xyz+3\sqrt[3]{abcx^2y^2z^2}+3\sqrt[3]{a^2b^2c^2xyz}+abc$$

$$(x+a)(y+b)(z+c) \geq (\sqrt[3]{xyz}+\sqrt[3]{abc})^3$$

ដូចនេះ $\sqrt[3]{(x+a)(y+b)(z+c)} \geq \sqrt[3]{xyz}+\sqrt[3]{abc}$ ។

លំហាត់ទី៥

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b និង c ចូរស្រាយបញ្ជាក់ថា :

$$\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\ge\frac{3}{2}$$ ។

របៀបទី១ : តាមវិសមភាព $\textbf{Cauchy – Schwarz}$

$$(a_1b_1+a_2b_2+a_3b_3)^2\le({a_1}^2+{a_2}^2+{a_3}^2)({b_1}^2+{b_2}^2+{b_3}^2)$$

យក $a_1=\sqrt{\frac{a}{b+c}}$, $a_2=\sqrt{\frac{b}{c+a}}$, $a_3=\sqrt{\frac{c}{a+b}}$

និង $b_1=\sqrt{a(b+c)}$, $b_2=\sqrt{b(c+a)}$, $b_3=\sqrt{c(a+b)}$

$$(a+b+c)^2\le(\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b})(2ab+2bc+2ca)$$

គេទាញ $\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\ge\frac{(a+b+c)^2}{2(ab+bc+ca)}$ $\quad(1)$

តាមវិសមភាព $\textbf{AM – GM}$ គេមាន :

$$\frac{a^2+b^2}{2}+\frac{b^2+c^2}{2}+\frac{c^2+a^2}{2}\ge ab+bc+ac$$

ឬ $a^2+b^2+c^2\ge ab+bc+ca$

ឬ $(a+b+c)^2\ge 3(ab+bc+ca)$ $\quad(2)$

តាមវិសមភាព (1) និង (2) គេទាញបាន :

$$\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\ge\frac{3}{2}$$ ។

របៀបទី២ :

គេមាន $\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\geq\frac{3}{2}$

គេបាន $(\frac{a}{b+c}+1)+(\frac{b}{c+a}+1)+(\frac{c}{a+b}+1)\geq\frac{3}{2}+3$

ឬ $\frac{a+b+c}{b+c}+\frac{a+b+c}{c+a}+\frac{a+b+c}{a+b}\geq\frac{9}{2}$

ឬ $(a+b+c)(\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a})\geq\frac{9}{2}$

តាមវិសមភាព $\mathbf{AM-GM}$ គេមាន :

$$(a+b)+(b+c)+(c+a)\geq 3\sqrt[3]{(a+b)(b+c)(a+c)}$$

$$2(a+b+c)\geq 3\sqrt[3]{(a+b)(b+c)(c+a)} \quad (1)$$

$$\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a}\geq\frac{3}{\sqrt[3]{(a+b)(b+c)(c+a)}} \quad (2)$$

គុណវិសមភាព **(1)** និង **(2)** អង្គ និង អង្គគេបាន :

$$2(a+b+c)(\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a})\geq 9$$

គេទាញ $(a+b+c)(\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a})\geq\frac{9}{2}$ ពិត

ដូចនេះ $\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\geq\frac{3}{2}$ ។

លំហាត់ទី៦

គេឱ្យ x,y,z ជាបីចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា $\frac{1}{(x+y)^2}+\frac{1}{(y+z)^2}+\frac{1}{(z+x)^2}\geq\frac{2(x+y+z)}{(x+y)(y+z)(x+z)}$

តាមវិសមភាព $AM-GM$ គេមាន :

$$\frac{1}{(x+y)^2}+\frac{1}{(y+z)^2}\geq\frac{2}{(x+y)(y+z)}\quad(1)$$

$$\frac{1}{(y+z)^2}+\frac{1}{(z+x)^2}\geq\frac{2}{(y+z)(z+x)}\quad(2)$$

$$\frac{1}{(z+x)^2}+\frac{1}{(x+y)^2}\geq\frac{2}{(z+x)(x+y)}\quad(3)$$

បូកវិសមភាព $(1),(2)$ និង (3) គេបាន :

$$2\left[\frac{1}{(x+y)^2}+\frac{1}{(y+z)^2}+\frac{1}{(z+x)^2}\right]\geq\frac{4(x+y+z)}{(x+y)(y+z)(x+z)}$$

ដូចនេះ

$$\frac{1}{(x+y)^2}+\frac{1}{(y+z)^2}+\frac{1}{(z+x)^2}\geq\frac{2(x+y+z)}{(x+y)(y+z)(z+x)}$$ ។

លំហាត់ទី៧

ចូរស្រាយបញ្ជាក់វិសមភាព :

$$\sqrt{a^2+(1-b)^2}+\sqrt{b^2+(1-c)^2}+\sqrt{c^2+(1-a)^2}\geq\frac{3\sqrt{2}}{2}$$

ចំពោះគ្រប់ចំនួនពិត a,b,c ។

តាមវិសមភាព **Minkowsky** គេមាន :

$$\sqrt{x_1{}^2+y_1{}^2}+\sqrt{x_2{}^2+y_2{}^2}+\sqrt{x_3{}^2+y_3{}^2}\geq\sqrt{(x_1+x_2+x_3)^2+(y_1+y_2+y_3)^2}$$

យក $x_1=a\ ,\ x_2=b\ ,\ x_3=c$

និង $y_1=1-b\ ,\ y_2=1-c\ ,\ y_3=1-a$ និង $s=a+b+c$

គេបាន $(x_1+x_2+x_3)^2+(y_1+y_2+y_3)^2=s^2+(3-s)^2\geq\frac{9}{2}$

ព្រោះ $s^2+(3-s)^2=2s^2-6s+9=\frac{1}{2}[(2s-3)^2+9]\geq\frac{9}{2}$

ដូចនេះ

$$\sqrt{a^2+(1-b)^2}+\sqrt{b^2+(1-c)^2}+\sqrt{c^2+(1-a)^2}\geq\frac{3\sqrt{2}}{2}$$ ។

លំហាត់ទី៨ (Junior TST 2002, Romania)

បើ $a,b,c\in(0,1)$ ចូរបង្ហាញថា :

$$\sqrt{abc}+\sqrt{(1-a)(1-b)(1-c)}<1$$

យើងដឹងថាចំពោះ $x\in(0,1)$ គេមាន $\sqrt{x}<\sqrt[3]{x}$

ហេតុនេះ $\sqrt{abc}<\sqrt[3]{abc}\quad(1)$

និង $\sqrt{(1-a)(1-b)(1-c)}<\sqrt[3]{(1-a)(1-b)(1-c)}\quad(2)$

បូកវិសមភាព $(1)\,\&\,(2)$ គេបាន :

$$\sqrt{abc}+\sqrt{(1-a)(1-b)(1-c)}<\sqrt[3]{abc}+\sqrt[3]{(1-a)(1-b)(1-c)}\quad(3)$$

តាមវិសមភាព $AM-GM$ គេមាន :

$$\sqrt[3]{abc}\le\frac{a+b+c}{3}\quad(4)$$

$$\sqrt[3]{(1-a)(1-b)(1-c)}\le\frac{1-a+1-b+1-c}{3}=\frac{3-(a+b+c)}{3}\quad(5)$$

បូកវិសមភាព $(4)\,\&\,(5)$ គេបាន :

$$\sqrt[3]{abc}+\sqrt[3]{(1-a)(1-b)(1-c)}\le\frac{(a+b+c)+3-(a+b+c)}{3}$$

$$\sqrt[3]{abc}+\sqrt[3]{(1-a)(1-b)(1-c)}\le 1\quad(6)$$

តាមវិសមភាព $(3)\,\&\,(6)$ គេបាន :

$$\sqrt{abc}+\sqrt{(1-a)(1-b)(1-c)}<1$$ ពិត ។

លំហាត់ទី៩

គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរស្រាយថា $\frac{a+b}{\sqrt{c}}+\frac{b+c}{\sqrt{a}}+\frac{c+a}{\sqrt{b}}\geq\sqrt{a}+\sqrt{b}+\sqrt{c}+3$

តាមវិសមភាព $AM-GM$ គេមាន $a+b\geq 2\sqrt{ab}$

គេបាន $\frac{a+b}{\sqrt{c}}\geq 2\sqrt{\frac{ab}{c}}$ (1)

ស្រាយដូចគ្នាដែរគេបាន :

$\frac{b+c}{\sqrt{a}}\geq 2\sqrt{\frac{bc}{a}}$ (2) និង $\frac{c+a}{\sqrt{b}}\geq 2\sqrt{\frac{ca}{b}}$ (3)

បូកវិសមភាព $(1),(2)\,\&\,(3)$ គេបាន :

$$\frac{a+b}{\sqrt{c}}+\frac{b+c}{\sqrt{a}}+\frac{c+a}{\sqrt{b}}\geq 2\left(\sqrt{\frac{ab}{c}}+\sqrt{\frac{bc}{a}}+\sqrt{\frac{ca}{b}}\right)\quad(4)$$

ម្យ៉ាងទៀត $\sqrt{\frac{ab}{c}}+\sqrt{\frac{ca}{b}}\geq 2\sqrt{a}$ (5)

$\sqrt{\frac{bc}{a}}+\sqrt{\frac{ab}{c}}\geq 2\sqrt{b}$ (6) និង $\sqrt{\frac{bc}{a}}+\sqrt{\frac{ca}{b}}\geq 2\sqrt{c}$ (7)

បូកវិសមភាព $(5),(6)\,\&\,(7)$ គេបាន :

$$2\left(\sqrt{\frac{ab}{c}}+\sqrt{\frac{bc}{a}}+\sqrt{\frac{ca}{b}}\right)\geq 2(\sqrt{a}+\sqrt{b}+\sqrt{c})\geq\sqrt{a}+\sqrt{b}+\sqrt{c}+3\ (8)$$

ព្រោះ $\sqrt{a}+\sqrt{b}+\sqrt{c}\geq 3\sqrt[3]{abc}=3$ ($abc=1$)

តាម $(4)\,\&\,(8)$ គេបាន $\frac{a+b}{\sqrt{c}}+\frac{b+c}{\sqrt{a}}+\frac{c+a}{\sqrt{b}}\geq\sqrt{a}+\sqrt{b}+\sqrt{c}+3$ ។

លំហាត់ទី១០

គេឱ្យ $\mathbf{a,b,c,d}$ ជាបួនចំនួនពិតដែល $\mathbf{a^2+b^2+c^2+d^2=4}$ ។

ចូរស្រាយបញ្ជាក់ថា $\mathbf{a^3+b^3+c^3+d^3 \le 8}$ ។

គេមាន $\mathbf{a^2+b^2+c^2+d^2=4}$

គេទាញ $\mathbf{b^2+c^2+d^2=4-a^2 \ge 0}$ ឬ $\mathbf{a^2 \le 4}$ ឬ $\mathbf{a \le 2}$

ដោយ $\mathbf{a^2 \ge 0}$ នោះ $\mathbf{a^3 \le 2a^2}$ **(1)**

ស្រាយដូចគ្នាដែរ $\mathbf{b^3 \le 2b^2}$ **(2)** , $\mathbf{c^3 \le 2c^2}$ **(3)** , $\mathbf{d^3 \le 2d^2}$ **(4)**

បូកវិសមភាព **(1),(2),(3) & (4)** អង្គ និង អង្គគេបាន :

$\mathbf{a^3+b^3+c^3+d^3 \le 2(a^2+b^2+c^2+d^2)=8}$ ពិត

ដូចនេះ $\mathbf{a^3+b^3+c^3+d^3 \le 8}$ ។

លំហាត់ទី១១

គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមាន ។

ចូរស្រាយថា $a^3+b^3+c^3-3abc \geq 2(\frac{b+c}{2}-a)^3$ ។

តាមវិសមភាព $AM-GM$ គេមាន $a^3+b^3+c^3 \geq 3abc$

នោះ $a^3+b^3+c^3-3abc \geq 0$ ។

បើ $\frac{b+c}{2}-a \leq 0$ នោះវិសមភាពខាងលើពិតជានិច្ច ។

យើងឧបមាថា $\frac{b+c}{2}-a > 0$ ។

តាង $T = a^3+b^3+c^3-3abc-2(\frac{b+c}{2}-a)^3$

យក $b=a+2x$ និង $c=a+2y$ នោះ $b+c=2a+2x+2y$

ដែល $x \geq 0$, $y \geq 0$ ។

គេបាន :

$$T = a^3+(a+2x)^3+(a+2y)^3-3a(a+2x)(a+2y)-2(x+y)^3$$

បន្ទាប់ពីបង្រួមរួចគេបាន :

$$T = 12a(x^2-xy+y^2)+6(x+y)(x-y)^2 \geq 6(x+y)(x-y)^2$$

$$T = 6(\frac{b+c}{2}-a)(\frac{b-c}{2})^2 \geq 0$$ ពិត

ដូចនេះ $a^3+b^3+c^3-3abc \geq 2(\frac{b+c}{2}-a)^3$ ។

លំហាត់ទី១២

គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរបង្ហាញថា $\frac{a+b+c}{3}\ge\sqrt[5]{\frac{a^2+b^2+c^2}{3}}$ ។

ឧបមាថា $\frac{a+b+c}{3}\ge\sqrt[5]{\frac{a^2+b^2+c^2}{3}}$ ពិត

សមមូល $\left(\frac{a+b+c}{3}\right)^5\ge\frac{a^2+b^2+c^2}{3}$

សមមូល $(a+b+c)^5\ge 81(a^2+b^2+c^2)=81abc(a^2+b^2+c^2)$

តាមវិសមភាព $AM-GM$ គេមាន :

$$\frac{x^2+y^2}{2}+\frac{y^2+z^2}{2}+\frac{z^2+x^2}{2}\ge xy+yz+zx$$

$$x^2+y^2+z^2\ge xy+yz+zx$$

$$(x+y+z)^2-2(xy+yz+zx)\ge xy+yz+zx$$

$$(x+y+z)^2\ge 3(xy+yz+zx)$$

យក $x=ab$, $y=bc$, $z=ca$ គេបាន :

$(ab+bc+ca)^2\ge 3abc(a+b+c)$

នោះ $(a^2+b^2+c^2)(ab+bc+ca)^2\ge 3abc(a+b+c)(a^2+b^2+c^2)$

ដើម្បីស្រាយថា $(a+b+c)^5\ge 81abc(a^2+b^2+c^2)$ ពិត

យើងត្រូវស្រាយថា $(a+b+c)^6\ge 27(a^2+b^2+c^2)(ab+bc+ca)^2$

តាង $\mathbf{T=(a+b+c)^6-27(a^2+b^2+c^2)(ab+bc+ca)^2}$

យក $\mathbf{S=a+b+c}$ និង $\mathbf{P=ab+bc+ca}$

នោះ $\mathbf{a^2+b^2+c^2=(a+b+c)^2-2(ab+bc+ca)=S^2-2P}$

គេបាន $\mathbf{T=S^6-27(S^2-2P)P^2}$

$$\mathbf{=S^6-27S^2P^2+54P^4}$$

$$\mathbf{=(S^2-3P)^2(S^2+6P^2)\geq 0}$$

ដូចនេះ $\mathbf{\dfrac{a+b+c}{3}\geq\sqrt[5]{\dfrac{a^2+b^2+c^2}{3}}}$ ។

លំហាត់ទី១៣

គេឱ្យ a,b,c ជាបីចំនួនពិតខុសគ្នា ។

ចូរស្រាយថា $\frac{a^2}{(b-c)^2}+\frac{b^2}{(c-a)^2}+\frac{c^2}{(a-b)^2}\geq 2$ ។

តាមសមភាព $(x+y+z)^2=x^2+y^2+z^2+2xy+2yz+2xz$

គេទាញ $x^2+y^2+z^2=(x+y+z)^2-2(xy+yz+zx)$

ដោយ $(x+y+z)^2\geq 0$ គ្រប់ចំនួនពិត x,y,z នោះគេបាន :

$x^2+y^2+z^2\geq -2(xy+yz+zx)$ (*)

យក $x=\frac{a}{b-c}$, $y=\frac{b}{c-a}$, $z=\frac{c}{a-b}$ នោះគេបាន :

$$xy+yz+zx=\frac{ab}{(b-c)(c-a)}+\frac{bc}{(a-b)(c-a)}+\frac{ac}{(a-b)(b-c)}$$
$$=\frac{ab(a-b)+bc(b-c)+ac(c-a)}{(a-b)(b-c)(c-a)}$$
$$=\frac{b(c-a)(b-c-a)+ac(c-a)}{(a-b)(b-c)(c-a)}$$
$$=\frac{(c-a)(b-c)(b-a)}{(a-b)(b-c)(c-a)}=-1$$

តាមទំនាក់ទំនង (*) គេទាញបាន $x^2+y^2+z^2\geq -2(-1)=2$

ដូចនេះ $\frac{a^2}{(b-c)^2}+\frac{b^2}{(c-a)^2}+\frac{c^2}{(a-b)^2}\geq 2$ ។

លំហាត់ទី១៤

គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមានដែល $a^2+b^2+c^2=a+b+c$ ។

ចូរស្រាយថា $a^2b^2+b^2c^2+c^2a^2\le ab+bc+ca$ ។

គេមាន $a^2+b^2+c^2=a+b+c$

គេបាន $(a^2+b^2+c^2)^2=(a+b+c)^2$

$$a^4+b^4+c^4+2(a^2b^2+b^2c^2+c^2a^2)=a^2+b^2+c^2+2(ab+bc+ca)$$

$$2(ab+bc+ca-a^2b^2-b^2c^2-c^2a^2)=a^4+b^4+c^4-a^2-b^2-c^2$$

តាមសមភាពនេះ ដើម្បីបង្ហាញថា $a^2b^2+b^2c^2+c^2a^2\le ab+bc+ca$

យើងត្រូវបង្ហាញថា $a^4+b^4+c^4\ge a^2+b^2+c^2$ ។

តាមវិសមភាព **Holder** គេមាន :

$$(a_1^3+a_2^3+a_3^3)(b_1^3+b_2^3+b_3^3)(c_1^3+c_2^3+c_3^3)\ge(a_1b_1c_1+a_2b_2c_2+a_3b_3c_3)^3$$

យក $a_1=b_1=a^{\frac{2}{3}}$, $a_2=b_2=b^{\frac{2}{3}}, a_3=b_3=c^{\frac{2}{3}}$

និង $c_1=a^{\frac{4}{3}}, c_2=b^{\frac{4}{3}}$, $c_3=c^{\frac{4}{3}}$ គេបាន

$$(a^2+b^2+c^2)^2(a^4+b^4+c^4)\ge(a^2+b^2+c^2)^3$$

នាំឱ្យ $a^4+b^4+c^4\ge a^2+b^2+c^2$ ពិត

ដូចនេះ $a^2b^2+b^2c^2+c^2a^2\le ab+bc+ca$ ។

លំហាត់ទី១៥

គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមាន ។ ចូរស្រាយថា :

$$(a^2+ab+b^2)(b^2+bc+c^2)(c^2+ca+a^2)\ge(ab+bc+ca)^3$$

តាមវិសមភាព $AM-GM$ គេមាន $x^2+y^2\ge 2xy$

នាំឱ្យ $x^2+y^2+3x^2+3y^2+4xy\ge 2xy+3x^2+3y^2+4xy$

ឬ $4(x^2+xy+y^2)\ge 3(x+y)^2$ គ្រប់ចំនួនពិតវិជ្ជមាន x និង y ។

ហេតុនេះចំពោះa,b,c ជាបីចំនួនពិតមិនអវិជ្ជមាន គេទាញបាន :

$$(a^2+ab+b^2)(b^2+bc+c^2)(c^2+ca+a^2)\ge(\frac{3}{4})^3(a+b)^2(b+c)^2(c+a)^2$$

យើងនឹងស្រាយថា : $(a+b)^2(b+c)^2(c+a)^2\ge(\frac{4}{3})^3(ab+bc+ca)^3$

គេមានសមភាព

$$(a+b)(b+c)(c+a)=a^2b+a^2c+ab^2+b^2a+ac^2+bc^2+2abc$$

$$(a+b+c)(ab+bc+ca)=a^2b+a^2c+ab^2+ab^2+ac^2+bc^2+3abc$$

ធ្វើផលដកសមភាពពីរនេះគេបាន

$$(a+b+c)(ab+bc+ca)-(a+b)(b+c)(c+a)=abc\ (1)$$

តាមវិសមភាព $AM-GM$ គេមាន $\begin{cases} a+b\ge 2\sqrt{ab} \\ b+c\ge 2\sqrt{bc} \\ c+a\ge 2\sqrt{ac}\end{cases}$

គេបាន $(a+b)(b+c)(c+a)\ge 8abc\quad(2)$

យក (1) ជំនួសក្នុង (2) គេបាន :

$$9(a+b)(b+c)(c+a)\ge 8(a+b+c)(ab+bc+ca)$$

ឬ $(a+b)^2(b+c)^2(a+c)^2\ge \frac{64}{81}(a+b+c)^2(ab+bc+ca)^2$ (3)

តាមវិសមភាព $AM-GM$ គេមាន :

$$\frac{a^2+b^2}{2}+\frac{b^2+c^2}{2}+\frac{c^2+a^2}{2}\ge ab+bc+ac$$

ឬ $a^2+b^2+c^2\ge ab+bc+ca$

ឬ $(a+b+c)^2\ge 3(ab+bc+ca)$ (4)

តាម (3) និង (4) គេទាញបាន :

$(a+b)^2(b+c)^2(c+a)^2\ge (\frac{4}{3})^3(ab+bc+ca)^3$ ពិត

ដូចនេះ

$$(a^2+ab+b^2)(b^2+bc+c^2)(c^2+ca+a^2)\ge (ab+bc+ca)^3$$

លំហាត់ទី១៦

គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមានដែល $abc=1$ ។ ចូរស្រាយថា :

$$\frac{c\sqrt{a^3+b^3}}{a^2+b^2}+\frac{a\sqrt{b^3+c^3}}{b^2+c^2}+\frac{b\sqrt{c^3+a^3}}{c^2+a^2}\ge\frac{3}{\sqrt{2}}$$ ។

តាង $T=\frac{c\sqrt{a^3+b^3}}{a^2+b^2}+\frac{a\sqrt{b^3+c^3}}{b^2+c^2}+\frac{b\sqrt{c^3+a^3}}{c^2+a^2}$

តាមវិសមភាព $\text{Cauchy}-\text{Schwarz}$ គេមាន :

$$(a^2+b^2)^2=(a^{\frac{1}{2}}.a^{\frac{3}{2}}+b^{\frac{1}{2}}.b^{\frac{3}{2}})^2\le(a+b)(a^3+b^3)$$

គេទាញ $a^2+b^2\le\sqrt{a+b}\,.\sqrt{a^3+b^3}$

ឬ $\frac{c\sqrt{a^3+b^3}}{a^2+b^2}\ge\frac{c}{\sqrt{a+b}}$ (1) ។ ស្រាយដូចគ្នាដែរគេបាន :

$\frac{a\sqrt{b^3+c^3}}{b^2+c^2}\ge\frac{a}{\sqrt{b+c}}$ (2) និង $\frac{b\sqrt{c^3+a^3}}{c^2+a^2}\ge\frac{b}{\sqrt{c+a}}$ (3)

បូកវិសមភាព (1),(2) & (3) គេបាន :

$$T\ge\frac{a}{\sqrt{b+c}}+\frac{b}{\sqrt{c+a}}+\frac{c}{\sqrt{a+b}}$$

តាមវិសមភាព $\text{Cauchy}-\text{Schwarz}$ គេបាន :

$$\left(\frac{a}{\sqrt{b+c}}+\frac{b}{\sqrt{c+a}}+\frac{c}{\sqrt{a+b}}\right)^2\ge3\left(\frac{a^2}{b+c}+\frac{b^2}{c+a}+\frac{c^2}{a+b}\right)\ (4)$$

ដោយ $a+b+c=\frac{a}{\sqrt{b+c}}.\sqrt{b+c}+\frac{b}{\sqrt{c+a}}.\sqrt{c+a}+\frac{c}{\sqrt{a+b}}\sqrt{a+b}$

គេបាន៖

$$(a+b+c)^2 \le [(b+c)+(c+a)+(a+b)](\frac{a^2}{b+c}+\frac{b^2}{c+a}+\frac{c^2}{a+b})$$

$$(a+b+c)^2 \le 2(a+b+c)(\frac{a^2}{b+c}+\frac{b^2}{c+a}+\frac{c^2}{a+b})$$

គេទាញ $\frac{a^2}{b+c}+\frac{b^2}{c+a}+\frac{c^2}{a+b} \ge \frac{a+b+c}{2} \ge \frac{3\sqrt[3]{abc}}{2} = \frac{3}{2}$ **(5)**

តាម **(4) & (5)** គេបាន $\left(\frac{a}{\sqrt{b+c}}+\frac{b}{\sqrt{c+a}}+\frac{c}{\sqrt{a+b}}\right)^2 \ge \frac{9}{2}$

នាំឱ្យ $\frac{a}{\sqrt{b+c}}+\frac{b}{\sqrt{c+a}}+\frac{c}{\sqrt{a+b}} \ge \frac{3}{\sqrt{2}}$ នោះ $T \ge \frac{3}{\sqrt{2}}$

ដូចនេះ $\frac{c\sqrt{a^3+b^3}}{a^2+b^2}+\frac{a\sqrt{b^3+c^3}}{b^2+c^2}+\frac{b\sqrt{c^3+a^3}}{c^2+a^2} \ge \frac{3}{\sqrt{2}}$ ។

លំហាត់ទី១៧

គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់វិសមភាព :

$$\sqrt{\frac{a^3}{a^3+(b+c)^3}}+\sqrt{\frac{b^3}{b^3+(c+a)^3}}+\sqrt{\frac{c^3}{c^3+(a+b)^3}}\ge 1$$ ។

តាង $S=\sqrt{\frac{a^3}{a^3+(b+c)^3}}+\sqrt{\frac{b^3}{b^3+(c+a)^3}}+\sqrt{\frac{c^3}{c^3+(a+b)^3}}$

យក $x=\frac{b+c}{a}$, $y=\frac{c+a}{b}$, $z=\frac{a+b}{c}$

គេបាន $S=\frac{1}{\sqrt{1+x^3}}+\frac{1}{\sqrt{1+y^3}}+\frac{1}{\sqrt{1+z^3}}$

តាមវិសមភាព $AM-GM$ គ្រប់ $u>0$ គេមាន :

$$1+x^3=(1+x)(1-x+x^2)\le\left(\frac{1+x+1-x+x^2}{2}\right)^2=(1+\frac{1}{2}x^2)^2$$

គេទាញបាន $\frac{1}{\sqrt{1+x^3}}\ge\frac{1}{1+\frac{1}{2}x^2}=\frac{1}{1+\frac{(b+c)^2}{2a^2}}$

ដោយ $1+\frac{(b+c)^2}{2a^2}\le 1+\frac{2(b^2+c^2)}{2a^2}=\frac{a^2+b^2+c^2}{a^2}$

គេទាញបាន $\frac{1}{\sqrt{1+x^3}}\ge\frac{a^2}{a^2+b^2+c^2}$

ដូចនេះ $S\ge\frac{a^2}{a^2+b^2+c^2}+\frac{b^2}{a^2+b^2+c^2}+\frac{c^2}{a^2+b^2+c^2}=1$ ។

លំហាត់ទី១៨

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c ចូរស្រាយថា :

$$\sqrt{\frac{a}{a+b}}+\sqrt{\frac{b}{b+c}}+\sqrt{\frac{c}{c+a}}\le\frac{3}{\sqrt{2}}$$

យក $S=\sqrt{\frac{a}{a+b}}+\sqrt{\frac{b}{b+c}}+\sqrt{\frac{c}{c+a}}$

តាង $x=\sqrt{\frac{b}{a}}$, $y=\sqrt{\frac{c}{b}}$, $z=\sqrt{\frac{a}{c}}$ ហើយ $xyz=1$

គេបាន $S=\frac{1}{\sqrt{1+x^2}}+\frac{1}{\sqrt{1+y^2}}+\frac{1}{\sqrt{1+z^2}}$

ឧបមាថា $x\ge y\ge z$ គេបាន $x^3\ge xyz=1$ ឬ $x\ge 1$ ហើយ $yz=\frac{1}{x}\le 1$

តាមវិសមភាព $\text{Cauchy}-\text{Schwarz}$ គេមាន :

$$\left(\frac{1}{\sqrt{1+y^2}}+\frac{1}{\sqrt{1+z^2}}\right)^2\le 2\left(\frac{1}{1+y^2}+\frac{1}{1+z^2}\right)$$

ដោយ $\frac{1}{1+y^2}+\frac{1}{1+z^2}=\frac{2+y^2+z^2}{1+y^2+z^2+z^2y^2}=1+\frac{1-y^2z^2}{1+y^2+z^2+y^2z^2}$

ហើយ $\frac{1-z^2y^2}{1+y^2+z^2+y^2z^2}\le\frac{(1-yz)(1+yz)}{1+2yz+y^2z^2}=\frac{1-yz}{1+yz}$

គេបាន $\left(\frac{1}{\sqrt{1+y^2}}+\frac{1}{\sqrt{1+z^2}}\right)^2\le 2\left(1+\frac{1-yz}{1+yz}\right)=\frac{4}{1+yz}$

គេទាញបាន $\frac{1}{\sqrt{1+y^2}}+\frac{1}{\sqrt{1+z^2}}\le\frac{2}{\sqrt{1+yz}}$

ហេតុនេះ $S\le\frac{1}{\sqrt{1+x^2}}+\frac{2}{\sqrt{1+yz}}$

យើងនឹងស្រាយថា $\frac{1}{\sqrt{1+x^2}}+\frac{2}{\sqrt{1+yz}}\le\frac{3}{\sqrt{2}}$

គេមាន $(1+x)^2\le 2(1+x^2)$ ឬ $1+x\le\sqrt{2}.\sqrt{1+x^2}$

នោះ $\frac{1}{\sqrt{1+x^2}}\le\frac{\sqrt{2}}{1+x}=\frac{\sqrt{2}}{1+\frac{1}{yz}}=\frac{\sqrt{2}yz}{1+yz}$

នាំឱ្យ $\frac{1}{\sqrt{1+x^2}}+\frac{2}{\sqrt{1+yz}}\le\frac{\sqrt{2}yz}{1+yz}+\frac{2}{\sqrt{1+yz}}$

ហើយ $\frac{3}{\sqrt{2}}-\frac{\sqrt{2}yz}{1+yz}-\frac{2}{\sqrt{1+yz}}=\frac{3(1+yz)-2yz-2\sqrt{2}\sqrt{1+yz}}{(1+yz)\sqrt{2}}$

$$=\frac{3+yz-2\sqrt{2}\sqrt{1+yz}}{(1+yz)\sqrt{2}}$$

$$=\frac{(\sqrt{2}-\sqrt{1+yz})^2}{(1+yz)\sqrt{2}}\ge 0$$

គេទាញ $\frac{1}{\sqrt{1+x^2}}+\frac{2}{\sqrt{1+yz}}\le\frac{\sqrt{2}yz}{1+yz}+\frac{2}{\sqrt{1+yz}}\le\frac{3}{\sqrt{2}}$ ពិត

ដូចនេះ $\sqrt{\frac{a}{a+b}}+\sqrt{\frac{b}{b+c}}+\sqrt{\frac{c}{c+a}}\le\frac{3}{\sqrt{2}}$ ។

លំហាត់ទី១៩

ចំពោះគ្រប់ចំនួនពិតមិនអវិជ្ជមាន x, y, z ចូរស្រាយថា :

$$2(1+x^2)(1+y^2)(1+z^2) \geq (1+x)(1+y)(1+z)(1+xyz)$$

បើ $y = z = x$ នោះវិសមភាពទៅជា $2(1+x^2)^3 \geq (1+x)^3(1+x^3)$

សមមូល $2(1+x^2)^3 - (1+x)^3(1+x^3) \geq 0$

សមមូល $(1-x)^4(1+x+x^2) \geq 0$ ពិត

ហេតុនេះគេបាន $\begin{cases} 2(1+x^2)^3 \geq (1+x)^3(1+x^3) \\ 2(1+y^2)^3 \geq (1+y)^3(1+y^3) \\ 2(1+z^2)^3 \geq (1+z)^3(1+z^3) \end{cases}$

គុណវិសមភាពនេះអង្គនិងអង្គគេបាន :

$$[2(1+x^2)(1+y^2)(1+z^2)]^3 \geq [(1+x)(1+y)(1+z)]^3 \times P$$

ឬ $2(1+x^2)(1+y^2)(1+z^2) \geq (1+x)(1+y)(1+z)\sqrt[3]{P}$ (*)

ដែល $P = (1+x^3)(1+y^3)(1+z^3)$

$$= 1 + (x^3+y^3+z^3) + (x^3y^3+y^3z^3+z^3x^3) + x^3y^3z^3$$

តាមវិសមភាព $AM - GM$ គេបាន :

$$P \geq 1 + 3\sqrt[3]{x^3y^3z^3} + 3\sqrt[3]{x^6y^6z^6} + x^3y^3z^3 = (1+xyz)^3$$

តាមទំនាក់ទំនង (*) គេបាន :

$2(1+x^2)(1+y^2)(1+z^2) \geq (1+x)(1+y)(1+z)(1+xyz)$ ពិត ។

លំហាត់ទី២០

ចំពោះគ្រប់ចំនួនពិតមិនអវិជ្ជមាន a,b,c,d ចូរស្រាយថា :

$$4(1-a+a^2)(1-b+b^2)(1-c+c^2)(1-d+d^2)\ge(1+abcd)^2$$

បើ $d=c=b=a$ វិសមភាពក្លាយជា $4(1-a+a^2)^4\ge(1+a^4)^2$

សមមូល $2(1-a+a^2)^2\ge 1+a^4$

សមមូល $2(1-a+a^2)^2-(1+a^4)=(1-a)^4\ge 0$ ពិត

ហេតុនេះ $\begin{cases}2(1-a+a^2)^2\ge 1+a^4\\ 2(1-b+b^2)^2\ge 1+b^4\end{cases}$

គេបាន $4(1-a+a^2)^2(1-b+b^2)^2\ge(1+a^4)(1+b^4)$

ដោយ $(1+a^4)(1+b^4)=1+(a^4+b^4)+a^4b^4\ge 1+2a^2b^2+a^4b^4$

ឬ $(1+a^4)(1+b^4)\ge(1+a^2b^2)^2$

គេទាញ $4(1-a+a^2)^2(1-b+b^2)^2\ge(1+a^2b^2)^2$

ឬ $2(1-a+a^2)(1-b+b^2)\ge 1+a^2b^2 \quad (1)$

ដូចគ្នាដែរ $2(1-c+c^2)(1-d+d^2)\ge 1+c^2d^2 \quad (2)$

ហើយ $(1+a^2b^2)(1+c^2d^2)\ge(1+abcd)^2$

ធ្វើផលគុណវិសមភាព (1) និង (2) គេបាន :

$$4(1-a+a^2)(1-b+b^2)(1-c+c^2)(1-d+d^2)\ge(1+abcd)^2$$

លំហាត់ទី២១ (Tournament of the Towns,1993)

បើសមីការ $x^4+ax^3+2x^2+bx+1=0$ មានឫសយ៉ាងតិចមួយជាចំនួនពិត នោះបង្ហាញថា $a^4+b^4\ge 8$ ។

តាង $x_0\in IR$ ដែល $x_0\ne 0$ ជាឫសរបស់សមីការនោះគេបាន :

$x_0{}^4+ax_0{}^3+2x_0{}^2+bx_0+1=0$ ឬ $ax_0{}^3+bx_0=-(x_0{}^2+1)^2$

តាមវិសមភាព $\textbf{Cauchy}-\textbf{Schwarz}$ គេបាន :

$$(x_0+1)^4=(ax_0{}^3+bx_0)^2\le(x_0{}^6+x_0{}^2)(a^2+b^2)$$

គេទាញ $a^2+b^2\ge\dfrac{(x_0{}^2+1)^4}{x_0{}^6+x_0{}^2}$

យើងនឹងស្រាយថា $\dfrac{(x_0{}^2+1)^4}{x_0{}^6+x_0{}^2}\ge 8$

គេមាន $(x_0{}^2+1)^4-8(x_0{}^6+x_0{}^2)=x_0{}^4-4x_0{}^3+6x_0{}^2-4x_0+1$

ឬ $(x_0{}^2+1)^4-8(x_0{}^6+x_0{}^2)=(x_0-1)^4\ge 0$

គេទាញបាន $\dfrac{(x_0{}^2+1)^4}{x_0{}^6+x_0{}^2}\ge 8$ ពិត

ដូចនេះ $a^4+b^4\ge 8$ ។

លំហាត់ទី២២

ចូរស្រាយបញ្ជាក់ថា :

$$\frac{a}{(b+c)^2}+\frac{b}{(c+a)^2}+\frac{c}{(a+b)^2}\ge\frac{9}{4(a+b+c)}$$

ចំពោះគ្រប់ a,b,c ជាចំនួនពិតវិជ្ជមាន ។

តាមវិសមភាព **Cauchy – Schwarz** :

$$(a_1^2+a_2^2+a_3^2)(b_1^2+b_2^2+b_3^2)\ge(a_1b_1+a_2b_2+a_3b_3)^2$$

យក $a_1=\frac{\sqrt{a}}{b+c}\ ,\ a_2=\frac{\sqrt{b}}{c+a}, a_3=\frac{\sqrt{c}}{a+b}$

និង $b_1=\sqrt{a}\ ,\ b_2=\sqrt{b}\ ,\ b_3=\sqrt{c}$ គេបាន :

$$\left[\frac{a}{(b+c)^2}+\frac{b}{(c+a)^2}+\frac{c}{(a+b)^2}\right](a+b+c)\ge\left(\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\right)^2$$

ដោយ $\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\ge\frac{3}{2}$ (មើលលំហាត់ទី៥)

គេទាញ $\left[\frac{a}{(b+c)^2}+\frac{b}{(c+a)^2}+\frac{c}{(a+b)^2}\right](a+b+c)\ge\frac{9}{4}$

ដូចនេះ $\frac{a}{(b+c)^2}+\frac{b}{(c+a)^2}+\frac{c}{(a+b)^2}\ge\frac{9}{4(a+b+c)}$ ។

លំហាត់ទី២៣ (JBMO 2002 Shortlist)

ចូរស្រាយបញ្ជាក់ថា $\frac{a^3}{b^2}+\frac{b^3}{c^2}+\frac{c^3}{a^2}\ge\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}$

ចំពោះគ្រប់ a,b,c ជាចំនួនពិតវិជ្ជមាន ។

តាមវិសមភាព Cauchy – Schwarz :

$$(a_1{}^2+a_2{}^2+a_3{}^2)(b_1{}^2+b_2{}^2+b_3{}^2)\ge(a_1b_1+a_2b_2+a_3b_3)^2$$

យក $a_1=\sqrt{a}$, $a_2=\sqrt{b}$, $a_3=\sqrt{c}$

និង $b_1=\frac{a\sqrt{a}}{b}$, $b_2=\frac{b\sqrt{b}}{c}$, $b_3=\frac{c\sqrt{c}}{a}$ គេបាន :

$$(a+b+c)\left(\frac{a^3}{b^2}+\frac{b^3}{c^2}+\frac{c^3}{a^2}\right)\ge\left(\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}\right)^2 \quad (1)$$

បើគេយក $a_1=\frac{a}{\sqrt{b}}$, $a_2=\frac{b}{\sqrt{c}}$, $a_3=\frac{c}{\sqrt{a}}$

និង $b_1=\sqrt{b}$, $b_2=\sqrt{c}$, $b_3=\sqrt{a}$ គេបាន :

$$\left(\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}\right)(a+b+c)\ge(a+b+c)^2 \quad (2)$$

គុណវិសមភាព (1) និង (2) អង្គ និង អង្គ រួចសម្រួលកត្តា $(a+b+c)^2$

និង $\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}$ គេបាន $\frac{a^3}{b^2}+\frac{b^3}{c^2}+\frac{c^3}{a^2}\ge\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}$ ពិត ។

ដូចនេះ $\frac{a^3}{b^2}+\frac{b^3}{c^2}+\frac{c^3}{a^2}\ge\frac{a^2}{b}+\frac{b^2}{c}+\frac{c^2}{a}$ ។

លំហាត់ទី២៤ (Crux Mathematicorum)

គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់ថា :

$$\frac{x}{x+\sqrt{(x+y)(x+z)}}+\frac{y}{y+\sqrt{(y+z)(y+x)}}+\frac{z}{z+\sqrt{(z+x)(z+y)}}\le 1$$

គេមាន $(x+y)(x+z)=x^2+xy+yz+xz\ge xy+2x\sqrt{yz}+zx$

$$(x+y)(x+z)\ge(\sqrt{xy}+\sqrt{xz})^2$$

$$\sqrt{(x+y)(x+z)}\ge\sqrt{xy}+\sqrt{xz}$$

$$x+\sqrt{(x+y)(x+z)}\ge x+\sqrt{xy}+\sqrt{xz}=\sqrt{x}(\sqrt{x}+\sqrt{y}+\sqrt{z})$$

គេទាញ $\frac{x}{x+\sqrt{(x+y)(x+z)}}\le\frac{\sqrt{x}}{\sqrt{x}+\sqrt{y}+\sqrt{z}}$ **(1)**

ស្រាយដូចគ្នាដែរ $\frac{y}{y+\sqrt{(y+z)(y+x)}}\le\frac{\sqrt{y}}{\sqrt{x}+\sqrt{y}+\sqrt{z}}$ **(2)**

និង $\frac{z}{z+\sqrt{(z+x)(z+y)}}\le\frac{\sqrt{z}}{\sqrt{x}+\sqrt{y}+\sqrt{z}}$ **(3)**

ធ្វើផលបូកវិសមភាព **(1), (2) & (3)** គេបាន :

$$\frac{x}{x+\sqrt{(x+y)(x+z)}}+\frac{y}{y+\sqrt{(y+z)(y+x)}}+\frac{z}{z+\sqrt{(z+x)(z+y)}}\le 1$$

លំហាត់ទី២៥

គ្រប់ចំនួនពិតវិជ្ជមាន a,b,c ចូរស្រាយបញ្ជាក់ថា :

$$\frac{b+c}{a}+\frac{c+a}{b}+\frac{a+b}{c}\geq 4\left(\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\right)$$

តាមវិសមភាព $AM-GM$ គ្រប់ $x>0$, $y>0$ គេមាន :

$$\frac{x+y}{2}\geq\sqrt{xy}$$

ឬ $(x+y)^2\geq 4xy$

ឬ $\frac{4}{x+y}\leq\frac{x+y}{xy}=\frac{1}{x}+\frac{1}{y}$

យក $x=\frac{b}{a}$ និង $y=\frac{c}{a}$ គេបាន $\frac{4a}{b+c}\leq\frac{a}{b}+\frac{a}{c}$ (1)

ដូចគ្នាដែរ $\frac{4b}{c+a}\leq\frac{b}{c}+\frac{b}{a}$ (2) និង $\frac{4c}{a+b}\leq\frac{c}{a}+\frac{c}{b}$ (3)

ធ្វើផលបូកវិសមភាព (1),(2) & (3) គេបាន :

$$\frac{4a}{b+c}+\frac{4b}{c+a}+\frac{4c}{a+b}\leq\frac{a+b}{c}+\frac{b+c}{a}+\frac{c+a}{b}$$

ដូចនេះ $\frac{b+c}{a}+\frac{c+a}{b}+\frac{a+b}{c}\geq 4\left(\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\right)$ ។

លំហាត់ទី២៦ (MOSP,2001)

គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមានដែល $abc=1$ ។

ចូរស្រាយថា $(a+b)(b+c)(c+a)\ge 4(a+b+c-1)$

មាន $(a+b+c)(ab+bc+ca)-(a+b)(b+c)(c+a)=abc \ (1)$

តាមវិសមភាព $AM-GM$ គេមាន :

$$(a+b)(b+c)(a+c)\ge 2\sqrt{ab}.2\sqrt{bc}.2\sqrt{ac}=8abc \quad (2)$$

យក (1) ជំនួសក្នុង (2) គេបាន :

$$(a+b)(b+c)(c+a)\ge \frac{8}{9}(a+b+c)(ab+bc+ca)$$

ដើម្បីបង្ហាញថា $(a+b)(b+c)(c+a)\ge 4(a+b+c-1)$

យើងត្រូវស្រាយថា $\frac{8}{9}(a+b+c)(ab+bc+ca)\ge 4(a+b+c-1)$ ពិត

ឬ $\frac{2}{9}.(ab+bc+ca)+\frac{1}{a+b+c}\ge 1$ ពិត

តាមវិសមភាព $AM-GM$ គេបាន :

$$\frac{ab+bc+ca}{9}+\frac{ab+bc+c}{9}+\frac{1}{a+b+c}\ge 3\sqrt[3]{\frac{(ab+bc+ca)^2}{81(a+b+c)}}$$

ឬ $\frac{2}{9}(ab+bc+ca)+\frac{1}{a+b+c}\ge \sqrt[3]{\frac{(ab+bc+ca)^2}{3(a+b+c)}}\ge 1$ ពិត

ព្រោះ $(ab+bc+ca)^2\ge 3abc(a+b+c)=3(a+b+c)$ ។

ដូចនេះ $(a+b)(b+c)(c+a)\ge 4(a+b+c-1)$ ។

លំហាត់ទី២៧ (APMO,2004)

ចូរបង្ហាញថា $(a^2+2)(b^2+2)(c^2+2)\ge 9(ab+bc+ca)$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c ។

គេមាន $(a+b+c)^2\ge 3(ab+bc+ca)$

ដើម្បីបង្ហាញថា $(a^2+2)(b^2+2)(c^2+2)\ge 9(ab+bc+ca)$

យើងត្រូវបង្ហាញថា $(a^2+2)(b^2+2)(c^2+2)\ge 3(a+b+c)^2$

គេមាន $\dfrac{u^2+2}{3}=1+\dfrac{u^2-1}{3}$ នោះវិសមភាពអាចសរសេរ :

$$(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge\frac{(a+b+c)^2}{9}$$

តាមសមភាព $(1+x)(1+y)=1+x+y+xy$

បើ x និង y មានសញ្ញាដូចគ្នានោះ $xy\ge 0$

ហេតុនេះ $(1+x)(1+y)\ge 1+x+y$ គ្រប់ចំនួនពិត x,y ។

-បើ $x\ge 0$, $y\ge 0$, $z\ge 0$ ឬ $x\le 0, y\le 0$, $z\ge 0$ គេបាន :

$$(1+x)(1+y)(1+z)\ge(1+x+y)(1+z)\ge 1+x+y+z \quad (1)$$

-បើ $-1<x<0$, $-1<y<0$,$-1<z<0$ នោះ $x+y$ និង z

មានសញ្ញាដូចគ្នា ហើយ $(1+x+y)(1+z)\ge 1+x+y+z$

គេបាន $(1+x)(1+y)(1+z)\ge 1+x+y+z$

យើងសិក្សាវិសមភាពតាមបីករណីដូចខាងក្រោម :

1-បើ $a,b,c\ge 1$ នោះ $\frac{a^2-1}{3}\ge 0,\frac{b^2-1}{3}\ge 0,\frac{c^2-1}{3}\ge 0$

តាមលក្ខណៈ (1) គេបាន :

$$(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge 1+\frac{a^2+b^2+c^2-3}{3}$$

$$(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge \frac{a^2+b^2+c^2}{3}$$

ដោយ $\frac{a^2+b^2+c^2}{3}\ge\frac{(a+b+c)^2}{9}$ (Cauchy – Schwarz)

គេបាន $(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge\frac{(a+b+c)^2}{9}$ ពិត

2-បើ $0<a,b,c<1$ នោះ $\frac{a^2-1}{3}<0,\frac{b^2-1}{3}<0,\frac{c^2-1}{3}<0$

តាមលក្ខណៈ (2) គេបាន :

$$(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge 1+\frac{a^2+b^2+c^2-3}{3}$$

$$(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge\frac{a^2+b^2+c^2}{3}\ge\frac{(a+b+c)^2}{9}$$ ពិត

3-បើ a,b,c មានពីរដែលធំជាង 1 នោះយើងសន្មតថា $a\ge 1,b\ge 1,c<1$

គេបាន $(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})\ge 1+\frac{a^2+b^2-2}{3}=\frac{1+a^2+b^2}{3}$

នោះ $(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\ge\frac{(1+a^2+b^2)(c^2+2)}{9}$

ដោយ $(1+a^2+b^2)(c^2+1+1)\geq(a+b+c)^2$

គេបាន $(1+\frac{a^2-1}{3})(1+\frac{b^2-1}{3})(1+\frac{c^2-1}{3})\geq\frac{(a+b+c)^2}{9}$ ពិត ។

4-ចំពោះករណី ដែលត្រីធាតុ a,b,c មានតែមួយគត់ដែលធំជាង 1 សិក្សាដូច

ករណីទី1 ។

សរុបចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c គេបាន :

$(a^2+2)(b^2+2)(c^2+2)\geq 9(ab+bc+ca)$ ។

លំហាត់ទី២៨ (Japan,1997)

គេយក a,b,c ជាបីចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{(b+c-a)^2}{(b+c)^2+a^2}+\frac{(c+a-b)^2}{(c+a)^2+b^2}+\frac{(a+b-c)^2}{(a+b)^2+c^2}\geq\frac{3}{5}$$

តាង $T=\frac{(b+c-a)^2}{(b+c)^2+a^2}+\frac{(c+a-b)^2}{(c+a)^2+b^2}+\frac{(a+b-c)^2}{(a+b)^2+c^2}$

យក $x=\frac{b+c}{a}$, $y=\frac{c+a}{b}$, $z=\frac{a+b}{c}$

គេបាន $\frac{1}{1+x}+\frac{1}{1+y}+\frac{1}{1+z}=\frac{a+b+c}{a+b+c}=1$ ហើយកន្សោម T ទៅជា

$T=\frac{(x-1)^2}{x^2+1}+\frac{(y-1)^2}{y^2+1}+\frac{(z-1)^2}{z^2+1}$ ។

បើ $x=y=z=2$ គេបាន $T=\frac{3}{5}$ ជាករណីដែលវិសមភាពក្លាយជាសមភាព ។

យើងសន្មតថាមានពីរចំនួនពិត a និង b ដែលនាំឱ្យ $\frac{(x-1)^2}{x^2+1}\geq\frac{a}{x+1}+b$ ពិត

គ្រប់ $x>0$ ហើយដោយ $\frac{1}{x+1}+\frac{1}{y+1}+\frac{1}{z+1}=1$ នោះដើម្បីឱ្យ $T\geq\frac{3}{5}$

លុះត្រាតែ $(\frac{a}{x+1}+b)+(\frac{a}{y+1}+b)+(\frac{a}{z+1}+b)=\frac{3}{5}$

នាំឱ្យ $a+3b=\frac{3}{5}\,(*)$

ម្យ៉ាងទៀតដោយសមភាពកើតឡើងចំពោះ $x=2$ នោះ $x=2$ ជាឫសឌុប

របស់សមីការ $\frac{(x-1)^2}{x^2+1}=\frac{a}{x+1}+b$

ឬ $(x+1)(x-1)^2-(x^2+1)(a+b+bx)=0$

តាង $f(x)=(x+1)(x-1)^2-(x^2+1)(a+b+bx)$

$x=2$ ជាឫសឌុបនៃ $f(x)=0$ នោះ $f'(2)=0$

ដោយ $f'(x)=(x-1)^2+2(x^2-1)-2x(a+b+bx)-b(x^2+1)$

នោះ $f'(2)=1+6-4(a+3b)-5b=7-4\times\frac{3}{5}-5b=0$

គេទាញបាន $b=\frac{23}{25}$ ហើយតាម (*) គេបាន $a=\frac{3}{5}-3b=-\frac{54}{25}$

គេបាន $\frac{(x-1)^2}{x^2+1}\geq\frac{23}{25}-\frac{54}{25(x+1)}$ សមមូល $\frac{2(x-2)^2(x+7)}{25(x+1)(x^2+1)}\geq 0$ ពិត

ហេតុនេះ $\frac{(x-1)^2}{x^2+1}\geq\frac{23}{25}-\frac{54}{25(x+1)}\,(1)$

$\frac{(y-1)^2}{y^2+1}\geq\frac{23}{25}-\frac{54}{25(y+1)}\,(2)$ និង $\frac{(z-1)^2}{z^2+1}\geq\frac{23}{25}-\frac{54}{25(z+1)}\,(3)$

បូកវិសមភាព $(1),(2)\,\&\,(3)$ គេបាន :

$$T\geq\frac{23}{25}\times 3-\frac{54}{25}\left(\frac{1}{x+1}+\frac{1}{y+1}+\frac{1}{z+1}\right)=\frac{69-54}{25}=\frac{15}{25}=\frac{3}{5}$$ ពិត

ដូចនេះ $\frac{(b+c-a)^2}{(b+c)^2+a^2}+\frac{(c+a-b)^2}{(c+a)^2+b^2}+\frac{(a+b-c)^2}{(a+b)^2+c^2}\geq\frac{3}{5}$ ។

លំហាត់ទី២៩

គេឱ្យ x,y,z,t ជាបួនចំនួនពិតវិជ្ជមាន ។ ចូរស្រាយថា :

$$\left(\frac{x}{x+y}\right)^2+\left(\frac{y}{y+z}\right)^2+\left(\frac{z}{z+t}\right)^2+\left(\frac{t}{t+x}\right)^2\geq 1$$ ។

តាង $a=\frac{y}{x}$, $b=\frac{z}{y}$, $c=\frac{t}{z}$ និង $d=\frac{x}{t}$ ដែល $abcd=1$

វិសមភាពសមមូល $\frac{1}{(1+a)^2}+\frac{1}{(1+b)^2}+\frac{1}{(1+c)^2}+\frac{1}{(1+d)^2}\geq 1$

តាមវិសមភាព $\text{Cauchy}-\text{Schwarz}$ គេមាន :

$$\frac{1}{(1+a)^2}+\frac{1}{(1+b)^2}-\frac{1}{1+ab}=\frac{ab(a-b)^2+(1-ab)^2}{(1+a)^2(1+b)^2(1+ab)}\geq 0$$

គេទាញ $\frac{1}{(1+a)^2}+\frac{1}{(1+b)^2}\geq\frac{1}{1+ab}$ (1)

ស្រាយដូចគ្នាដែរ $\frac{1}{(1+c)^2}+\frac{1}{(1+d)^2}\geq\frac{1}{1+cd}=\frac{ab}{1+ab}$ (2)

បូកវិសមភាព (1) & (2) គេបាន :

$$\frac{1}{(1+a)^2}+\frac{1}{(1+b)^2}+\frac{1}{(1+c)^2}+\frac{1}{(1+d)^2}\geq\frac{1}{1+ab}+\frac{ab}{1+ab}=1$$

ដូចនេះ $\left(\frac{x}{x+y}\right)^2+\left(\frac{y}{y+z}\right)^2+\left(\frac{z}{z+t}\right)^2+\left(\frac{t}{t+x}\right)^2\geq 1$ ។

លំហាត់ទី៣០

គេឱ្យ a, b, c និង x, y, z ជាចំនួនពិត ។ ចូរស្រាយបញ្ជាក់ថា :

$$4(a^2+x^2)(b^2+y^2)(c^2+z^2) \geq 3(bcx+cay+abz)^2$$

តាមវិសមភាព Cauchy – Schwarz គេមាន :

$$[x(bc)+a(cy+bz)]^2 \leq (x^2+a^2)[b^2c^2+(cy+bz)^2]$$

ឬ $(a^2+x^2)[b^2c^2+(cy+bz)^2] \geq (bcx+acy+abz)^2$

ដើម្បីស្រាយថា $4(a^2+x^2)(b^2+y^2)(c^2+z^2) \geq 3(bcx+cay+abz)^2$

យើងគ្រាន់តែស្រាយថា $4(b^2+x^2)(c^2+z^2) \geq 3[b^2c^2+(cy+bz)^2]$

ឬ $4(b^2+x^2)(c^2+z^2) - 3[b^2c^2+(cy+bz)^2] \geq 0$

